ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៦...១០៤ (ប្រ.ក)

ស្រង់ចេញ
ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ 2006

## ប្រកាស

## ស្តីពី

## ការបង្កើតក្រុមប្រតិបត្តិ និងលេខាធិការដ្ឋាននៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- តាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦

## សំរេច

**ប្រការ ១.-**

បង្កើតក្រុមប្រតិបត្តិ ដើម្បីដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS) ដែលរួមមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក ហ៊ុល សាភា | ប្រធានការិយាល័យព័ត៌មានុសាស្ត្រ | ប្រធាន |
| ២- អ្នកស្រី ហេង គីរិយា | ប្រធានផ្នែកការិយាល័យព័ត៌មានុសាស្ត្រ | អនុប្រធាន |



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

| | | |
|---|---|---|
| ៣- លោក ហៃ កាមីន | អនុប្រធានផ្នែកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងវេបសាយ |
| ៤- លោក សោម វឌ្ឍនាថ | អនុប្រធានផ្នែកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងវេបសាយ |
| ៥- លោក សុង ឈាង | បុគ្គលិកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងវេបសាយ |
| ៦- លោក ជិន ណារុង | អនុប្រធានផ្នែកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ |
| ៧- អ្នកស្រី ណឹម សុភ័ក្ត្រ | អនុប្រធានផ្នែកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ |
| ៨- លោក វ៉ៃ ស៊ុនហេង | អនុប្រធានផ្នែកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ |
| ៩- លោក ឌិន ពិសារ | បុគ្គលិកការិយាល័យព័ត៌មានសាស្ត្រ | អ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ |

**ប្រការ ២.-**

បង្កើតលេខាធិការដ្ឋានសម្រាប់ជាជំនួយការ រៀបចំរបាយការណ៍ និងចាត់ចែងការងារផ្សេងៗតាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រងនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- លោក ហ៊ុល សាភា | ប្រធានការិយាល័យព័ត៌មានសាស្ត្រ | ប្រធាន |
| ២- លោក ហៃ កាមីន | អនុប្រធានផ្នែកការិយាល័យព័ត៌មានសាស្ត្រ | អនុប្រធាន |
| ៣- លោក សោម កុសុម | អនុប្រធានផ្នែក នាយកដ្ឋានត្រួតពិនិត្យ | សមាជិក |
| ៤- លោក ជា តុលា | អនុប្រធានផ្នែក នាយកដ្ឋានប្រតិបត្តិការ | សមាជិក |

**ប្រការ ៣.-**

ក្រុមប្រតិបត្តិនៃប្រការ១ ខាងលើមានមុខងារ និងភារកិច្ចដូចខាងក្រោម ៖

**ប្រធានក្រុមប្រតិបត្តិត្រូវ** ៖

- គ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការប្រចាំថ្ងៃរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានអ្នកគ្រប់គ្រងគេហទំព័រ (Web) និងអ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ (Database) ជាជំនួយការ ។
- ក្នុងករណីដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានបញ្ហាខូចខាត ប្រធានក្រុមប្រតិបត្តិត្រូវអនុវត្តនីតិវិធីស្តារឡើងវិញជាបន្ទាន់ ហើយត្រូវរាយការណ៍លទ្ធផលនេះជូនទៅប្រធានគណៈកម្មាធិការគ្រប់គ្រងភ្លាម ។

**អ្នកគ្រប់គ្រងសេវា Web ត្រូវ** ៖

- រក្សា និងការពារ CIS Web Server ប្រឆាំងវីរុស (virus) ការជ្រៀតចូលបំផ្លាញប្រព័ន្ធ និងការខូចខាតទ្រព្យសម្បត្តិខាងក្រៅផ្សេងៗ

- គ្រប់គ្រងអត្តសញ្ញាណអ្នកប្រើប្រាស់សេវាធនាគារ (Bank User IDs) ដោយអនុញ្ញាត ព្យួរ ឬលុបចោល និងឆ្លើយតបទូរសារ (e-mail) ជាមួយអ្នកប្រើប្រាស់ ក្នុងករណីដែលមានការផ្លាស់ប្តូរស្ថានភាពរបស់អ្នកប្រើប្រាស់
- ឆ្លើយតបទៅនឹងរាល់សំនួររបស់ធនាគារជាសមាជិក
- ជូនដំណឹងដល់ធនាគារជាសមាជិកនូវរាល់ការផ្លាស់ប្តូរដែលកើតមានទៅលើការប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និង បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- តាមដានភារកិច្ចរបស់អ្នកចុះបញ្ជីទិន្នន័យធនាគារ ដើម្បីថែរក្សាទំព័រស្នើសុំត្រួតពិនិត្យ (Check Request Page)
- តាមដានការផ្ទុកព័ត៌មានក្នុងប្រព័ន្ធ និងសកម្មភាពរបស់អ្នកប្រើប្រាស់
- បង្កើតការប្រើប្រាស់ប្រព័ន្ធដែលទាក់ទងទៅនឹងស្ថិតិ
- បង្កើតកន្លែងដើម្បីរក្សាទុកព័ត៌មាន (back up) តាមការកំណត់
- រៀបចំរបាយការណ៍ប្រចាំខែអំពីការប្រព្រឹត្តខុសច្បាប់ និងបទប្បញ្ញត្តិដោយធនាគារជាសមាជិក និងរាយការណ៍ជូនប្រធានក្រុមប្រតិបត្តិ
- រាយការណ៍នូវសកម្មភាពសង្ស័យផ្សេងៗ នៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជូនប្រធានក្រុមប្រតិបត្តិ
- ថែរក្សា និងកែសម្រួល (update) ក្បួនប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS user manuals) សម្រាប់ធនាគារជាសមាជិក អ្នកចុះបញ្ជីទិន្នន័យធនាគារ និងអ្នកប្រើប្រាស់ធនាគារ និងក្បួនសម្រាប់អ្នកគ្រប់គ្រងសេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

**អ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យ (Database Service) ត្រូវ ÷**

- រក្សា និងការពារ CIS Database Server ប្រឆាំងវីរុស ការជ្រៀតចូលបំផ្លាញប្រព័ន្ធ ការលុកលុយចូលកន្លែងហាមឃាត់ និងការខូចខាតទ្រព្យសម្បត្តិខាងក្រៅផ្សេងៗ
- បង្កើតកន្លែងដើម្បីរក្សាទុកព័ត៌មាន (back up) តាមការកំណត់
- រៀបចំកន្លែងរក្សាទុកព័ត៌មាន (back up) និងនីតិវិធីស្តារឡើងវិញជាបន្ទាន់
- តាមដានការផ្ទុកព័ត៌មានក្នុងប្រព័ន្ធ និងផែនការសម្រាប់តម្រូវការ HDD (Hard Disk Drive) បន្ថែម
- រាយការណ៍ពីសកម្មភាពសង្ស័យនានានៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជូនប្រធានក្រុមប្រតិបត្តិ ។

**ប្រការ ៤.-**

ប្រធានក្រុមប្រតិបត្តិមានសិទ្ធិអញ្ជើញសមាសភាពក្រុមប្រតិបត្តិ និងមន្ត្រីពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ និងធ្វើការងារតាមការចាំបាច់ ។ សមាសភាពក្រុមប្រតិបត្តិត្រូវទទួលខុសត្រូវគ្រប់កិច្ចការដែលប្រធានប្រគល់ឱ្យ ។

**ប្រការ ៥.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា និងសាមីជននៃប្រការ១ និងប្រការ២ ខាងលើ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៦

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល :**

- ដូចប្រការ ១ ប្រការ ២ និងប្រការ ៥ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"